## តើលោកអ្នកគិតថាសិទ្ធិរកផ្ទះសម្បែងដែលមានតម្លាភាព អាចត្រូវបានគេបំពាន ឬទេ?

### សរសេរទុក!!!

*រឿងសំខាន់បំផុតលោកអ្នកអាចជួយខ្លួនឯងបាន គឺសរសេរទុកឲ្យបានពិស្តារនូវអ្វីដែលបានកើតឡើង! បង្កើត "កំណត់ពេល" នៃអ្វីដែលបានកើតឡើង នៅពេលលោកអ្នកបានព្យាយាមជួល ឬទិញកន្លែងដើម្បីរស់នៅ ។*

*ប្រាកដជារួមបញ្ចូលទាំង :*

*ចំណុចសំខាន់ៗនៃអ្វីបានកើតមានឡើង (អ្នកណា, អ្វីខ្លះ, នៅកន្លែងណា, នៅពេលណា);*

*ឈ្មោះ, អាស័យដ្ឋាន និងលេខទូរស័ព្ទនៃមនុស្សទាំងអស់ដែលជាប់ទាក់ទង;*

*ការផ្សាយណាមួយលោកអ្នកបានឃើញអំពីផ្ទះសម្បែង;*

*ក្រដាសស្នាមណាមួយដែលគេបានជូនលោកអ្នក ។*

### សូមទាក់ទងមណ្ឌលផ្ទះសម្បែងដែលមានតម្លាភាពនៃតំបន់ក្រុង បុស្តុន!!

*មណ្ឌលនឹងធ្វើកិច្ចការដើម្បីដោះស្រាយបញ្ហាដោយធ្វើការជាមួយលោកអ្នកផ្ទាល់ ឬដោយបញ្ជូនសំណុំរឿងរបស់លោកអ្នកទៅឲ្យមេធាវី, ក្រសួងការផ្ទះសម្បែងសហរដ្ឋ និងការអភិវឌ្ឍន៍ជនបទ, ឬគណៈកម្មការប្រឆាំងការរើសអើងរដ្ឋម៉ាស្សាឈូសេត្ស ។ មណ្ឌលនឹងមិនធ្វើសកម្មភាពអ្វីឲ្យលោកអ្នកដោយគ្មានការអនុញ្ញាតឡើយ ។ លោកអ្នកអាចទាក់ទងយើងតាមរយៈទូរស័ព្ទលេខ (៦១៧) ៣៩៩-០៤៩១ ។*

***នៅពេលលោកអ្នកទូរស័ព្ទ សូមរង់ចាំក្នុងខណៈយើងតភ្ជាប់ជាមួយអ្នកបកប្រែ ។***

មណ្ឌលផ្ទះសម្បែងដែលមានតម្លាភាពនៃតំបន់ក្រុង បុស្តុន ធ្វើការដើម្បីបំបាត់នូវការរើសអើងខាងផ្ទះសម្បែង ហើយលើកដំកើងសហគមន៍យ៉ាងបើកចំហរពាសពេញតំបន់ ។

យើងបំរើសហគមន៍ក្នុងស្រុក

**Essex, Middlesex, Norfolk, Plymouth and Suffolk**

The Fair Housing Center of Greater Boston

59 Temple Place, #1105
Boston, MA 02111
Phone: 617.399.0491
Fax: 617.3990492

UNION LABEL RED SUN PRESS

*សំរាប់អ្នកដែលមានបញ្ហាស្តាប់ (TTY users)*
*សូមទាក់ទងតាមរយៈទូរស័ព្ទលេខ*

*១-៨០០-៨៣៩-២៣៧០*

E-mail: info@bostonfairhousing.org
www.bostonfairhousing.org

Khmer

# សិទ្ធិរកផ្ទះសម្បែងដែលមានតម្លាភាពរបស់លោកអ្នក :



បានរៀបចំឡើងដោយ

**មណ្ឌលផ្ទះសម្បែងដែលមានតម្លាភាពនៃតំបន់ក្រុង បុស្តុន**

*"លោកអ្នកត្រូវតែនិយាយភាសាអង់គ្លេសដើម្បីរស់នៅទីនេះ ។"*

*"យើងបានសំរេចចិត្តដកផ្ទះជួលចេញពីទីផ្សារបណ្តោះអាសន្នសិន ។"*

*"លោកអ្នកអាចនៅតំបន់ផ្សេងទៀតស្រួលជាង ។"*

*"យើងមិនទទួលយកផ្ទះជំនួយ សិកសិន ៨"*

*"យើងមិនអាចជួលផ្ទះនេះទេ--វាមិនទាន់សំអាតជាតិសំណពុលចេញ ។"*

*"SSI/SSDI មិនរាប់ជាប្រាក់ចំណូលដ៏ពិតប្រាកដនោះទេ ។"*

*"បំពេញសំណុំបែបបទពាក្យសុំ ហើយអ្នកណាម្នាក់នឹងទាក់ទងទៅលោកអ្នកវិញមិនខានឡើយ ។"*

*"ម្ចាស់ផ្ទះមិនចង់ឲ្យមានក្មេងនៅក្នុងផ្ទះនោះទេ ។"*

*តើទាំងនេះដូចជាធ្លាប់ឮ? បើសិនដូច្នោះមែន សិទ្ធិរកផ្ទះសម្បែងឲ្យមានតម្លាភាពរបស់លោកអ្នក អាចត្រូវបានគេបំពាន ។ ច្បាប់រដ្ឋ និងសហព័ន្ធ ចែងថាវាជាការខុសច្បាប់ចំពោះការរើសអើងនឹងអ្នករកផ្ទះសម្បែងយោលទៅលើរឿងរ៉ាវដូចជា ពូជសាសន៍, ដើមកំណើត ឬភាពពិការរបស់លោកអ្នក ។*

## ការឃោសនាផ្សាយ

*វាគឺល្មើសនឹងច្បាប់សំរាប់កាសែត, ម្ចាស់ផ្ទះ ឬភ្នាក់ងារលក់ទិញផ្ទះ បោះពុម្ពផ្សាយ ឬចេញសេចក្តីថ្លែងដោយមានភាពរើសអើង ។*

## កិច្ចព្រមព្រៀង និងល័ក្ខខ័ណ្ឌផ្សេងទៀត

*វាគឺការល្មើសនឹងច្បាប់ចំពោះការតម្រូវឲ្យមានប្រាក់កក់បន្ថែម ឬការបង់ថ្លៃជួល ឬប្រើសំណុំបែបបទពាក្យសុំពិបាកៗថែមទៀត ។*

## ការតម្រែតម្រង់

*វាគឺល្មើសនឹងច្បាប់ដើម្បី "តម្រែតម្រង់" អ្នករកផ្ទះសម្បែងទៅសហគមន៍, សង្កាត់ ឬកន្លែងផ្ទះឈ្នួលផ្សេងៗ ។*

រៀនដើម្បីកត់សំគាល់ការរើសអើង! ច្បាប់សហព័ន្ធនិងច្បាប់រដ្ឋចែងថា វាជាការខុសច្បាប់ចំពោះការរើសអើងក្នុងកិច្ចការផ្ទះសម្បែងពីព្រោះតែ ៖

*ពូជសាសន៍*
*ពណ៌សម្បុរ*
*ដើមកំណើត*
*សាសនា*
*ភេទ*
*ភាពពិការ*
*ស្ថានភាពគ្រួសារ*
*ប្រភពនៃប្រាក់ចំណូល (ជំនួយសាធារណៈ និង/ឬអ្នកទទួលជំនួយខាងផ្ទះសម្បែង)*
*ស្ថានភាពប្តីប្រពន្ធ*
*អាយុ (មិនរួមបញ្ចូលក្មេងមិនទាន់គ្រប់អាយុ)*
*របៀបរស់នៅទាក់ទងនឹងការរួមភេទ*
*ប្រវត្តិយោធា*

## ហេតុអ្វីបានជាលោកអ្នកគួរតែខ្វល់ខ្វាយដើម្បីតទ៉ាប្រឆាំងនឹងការរើសអើងខាងផ្ទះសម្បែង?

*បើសិនលោកអ្នកតវ៉ាប្រឆាំងនឹងការអនុវត្តន៍រើសអើងខាងផ្ទះសម្បែង លោកអ្នកអាចទទួលបាន :*

*ផ្ទះសម្បែងដែលលោកអ្នកចង់បាន;*

*ការសងថ្លៃដូចជា ថ្លៃរើចេញ ឬថ្លៃជួលផ្ទះបណ្តោះអាសន្ន;*

*បង់ថ្លៃជម្ងឺចិត្តដែលលោកអ្នកឈឺចាប់ដោយសារតែការរើសអើង;*

*សេចក្តីបញ្ជាដើម្បីហាមឃាត់មិនឲ្យមានការរើសអើងនៅពេលអនាគត ឬតម្រូវការឲ្យម្ចាស់ផ្ទះ/ភ្នាក់ងារ ជួលផ្ទះទៅឲ្យអ្នកដទៃទៀតដូចជាលោកអ្នកអញ្ចឹងដែរ;*

*បង់ថ្លៃមេធាវីរបស់លោកអ្នក (មេធាវីខ្លះនឹងមានការយោគយល់ដែលគេនឹងយកកម្រៃឈ្នួលលុះត្រាតែលោកអ្នកឈ្នះក្តីសិន);*

*សេចក្តីពេញចិត្តនៃការយល់ដឹងដែលលោកអ្នកបានតវ៉ាប្រឆាំងនឹងការរើសអើង ហើយអ្នកផ្សេងទៀតមិនអាចឆ្លងកាត់នូវការឈឺចាប់និងការធ្វើឲ្យមិនបានសម្រេច ដែលលោកអ្នកបានជួបប្រទះនោះ ។*